ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ០០៧/១៨ គ.ជ.ប.ជ

ថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

## សូមគោរពជូន
## លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**ជាទីគោរព**

**កម្មវត្ថុ៖** សូមគោរពជូន របាយការណ៍ស្តីពី កិច្ចប្រជុំពិភាក្សារវាងស្ថាប័នអយ្យការ និងមន្ត្រីសមត្ថកិច្ចជំនាញអនុវត្តច្បាប់ ដើម្បីប្រមូលធាតុចូលពាក់ព័ន្ធករណីពពោះជំនួសដែលត្រូវបានបង្ក្រាប កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីបន្តនីតិវិធី ។

**យោង៖** ការចាត់តាំងពីលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយផ្ទាល់ ចំពោះ ឯកឧត្តម ឯកឧត្តម ឧត្តមសេនីយឯក **ជីវ ផល្លី** អគ្គលេខាធិការរងគ.ជ.ប.ជទទួលបន្ទុកការងារអនុវត្តច្បាប់ និងនាងខ្ញុំ **រីន សិរីលក្ខិណា** អគ្គលេខាធិការរងគ.ជ.ប.ជ ទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ និងជាសមាជិកនៃក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ពពោះជំនួស ឲ្យចូលរួមក្នុងកិច្ចប្រជុំ រវាងស្ថាប័នអយ្យការ និងសមត្ថកិច្ចជំនាញនៅសាលាដំបូងរាជធានីភ្នំពេញ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ដោយមានការឯកភាពពីឯកឧត្តម ជីវ ផល្លី នាងខ្ញុំមានកិត្តិយសសូមគោរពរាយការណ៍ជូន **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាជ្រាប ថា នៅព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ នៅប្រជុំនៃបន្ទប់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ម៉ោង០៩.០០ ដល់ ម៉ោង១០.៤៥ មានកិច្ចប្រជុំពិភាក្សា មួយលើករណីពពោះ ដែលត្រូវបានបង្ក្រាប កាលពីថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៨ ដោយមានការចូលរួមពី ៖

**១.តំណាងអយ្យការ៖**

**.ឯកឧ. ព្រះរាជអាជ្ញា យ៉េត ចរិយា**

**.លោកព្រះរាជអាជ្ញារង សៀង សុខ**

**.លោកព្រះរាជអាជ្ញារង គុជ គឹមឡុង**

- លើកនេះនារីយល់ព្រមទទួលយក ៥០០ដុល្លា នៅពេលកូនមានបេះដូងលោត(កូនមានជីវិត) នៅខែបន្ទាប់ៗមកទៀតគេនឹងប្រគល់១ខែ៣០០$ រហូតដល់កើត និងត្រូវសម្រាលកូននៅមន្ទីរពេទ្យខ្មែរ ឬនៅប្រទេសចិនអាស្រ័យស្ថានភាព ហើយកូននោះនឹងត្រូវបានគេបំបែកយកទៅ ដោយមិនដឹងថាគេយកកូនទៅណាឡើយ ។
- ដូចនេះ ស្ត្រីពពោះ ពិតជាមានចេតនា និងដឹងជាមុន ថានឹងត្រូវឲ្យកូនទៅគេ ប្តូរយកលុយក្នុងតម្លៃព្រមព្រៀង។
- នៅមុនពេលបង្ក្រាប៣ថ្ងៃ មានស្ត្រីម្នាក់បានកើតកូនមុនពេលកំណត់ដោយវះកាត់ ដែលកូននោះមិនប្រក្រតីត្រូវសង្គ្រោះបន្ទាន់ បានបញ្ជូន ទៅពេទ្យកុមារជាតិ និងពេទ្យគន្ធបុប្ផា តែកូនត្រូវស្លាប់ ហើយសពកូននោះត្រូវបានគេទុកចោលនៅពេទ្យគន្ធបុប្ផា ។ ពេលសាកសួរស្ត្រីជាម្តាយ គាត់យំដោយបារម្ភក្រែងមិនបានទទួលប្រាក់ដែលគេសន្យាថាឲ្យ ព្រោះទារកនោះស្លាប់ តែមិនមែនគាត់យំសោកស្តាយជីវិតទារកទេ
- ករណីទាំង៣៣នាក់ ត្រូវបានរកឃើញថា ជាអ្នកធ្វើការតាមរោងចក្រ ដោយមានបណ្តាញអូសទាញជា Recruiter ចំពោះស្ត្រីមានជីវភាពលំបាក និងធ្វើតាមអ្នកមុនដែលមានបទពិសោធន៍រួចហើយ
- ដូច្នេះ ឧក្រិដ្ឋជនមានបណ្តាញចាត់តាំងច្បាស់លាស់ ។ មានស្ត្រីម្នាក់ជាជនសង្ស័យ ធ្លាប់បាននាំស្ត្រីទៅកើតនៅប្រទេសចិន ៥នាក់រួចហើយ ។

## ២- សរុបមតិរួមៈ

- យោងលើសេចក្តីជូនដំណឹងដែលបានចុះហត្ថលេខាដោយសម្តេចក្រឡាហោម អាចយកជាគោលគំនិតសម្រាប់វិនិច្ឆ័យទោស
- ស្នើសុំពិនិត្យច្បាប់ពាក់ព័ន្ធ
- គួរស៊ើបអង្កេតរកប្រភពមេជីវិត
- គួរគិតដល់វិធីនាំទារកចេញឬស្ត្រីមានផ្ទៃពោះជិតសម្រាលចេញ ដែលអាចពាក់ព័ន្ធមន្ត្រីតាមច្រកពាក់ព័ន្ធ ឬតាមច្រករបៀង
- គប្បីស្វះស្វែងស្រាវជ្រាវរកនូវចំណុចពាក់ព័ន្ធផ្សេងៗទៀត និងត្រូវជម្រុញការអនុវត្តច្បាប់ឲ្យបានតឹងរឹង
- បន្តកិច្ចសហការ ស្វែងរកបណ្តាញឧក្រិដ្ឋជន ទាំងនៅប្រទេសចិន និងក្នុងប្រទេសកម្ពុជា
- ត្រូវបន្តនីតិវិធីស្នើសុំពិនិត្យលើប្រព័ន្ធហិរញ្ញវត្ថុរបស់ជនសង្ស័យ
- កំណត់រកបទចោទចំពោះស្ត្រីដែលមានចេតនាផ្សំគំនិតក្នុងការពពោះ និងបង្កើតទារកដើម្បីជួញដូរដើម្បីជាការព្រមាន ។

**៣.សំណូមពរ៖**

៣.១ អង្គប្រជុំ

- សំណូមពរកុំទាន់អនុញ្ញាតស្ត្រីទាំងនោះត្រឡប់ទៅផ្ទះ ព្រោះនឹងពិបាកគ្រប់គ្រង ហើយអាចគាត់មិនរក្សាកូនក្នុងផ្ទៃជាពិសេស ទារកក្នុងផ្ទៃដែលទើបតែមានអាយុក្រោម ៣ ឬ៤ខែ
- ស្នើព្រះរាជអាជ្ញា ពិនិត្យអង្គហេតុ និងមាត្រាច្បាប់ពាក់ព័ន្ធ ដើម្បីផ្តើធ្វើការចោទប្រកាន់ជនសង្ស័យ ០៥នាក់ពីបទលក់ដូរមនុស្សឆ្លងដែន និងពិនិត្យបទចោទចំពោះស្ត្រីពពោះ។

៣.២ តំណាងអយ្យការ

- ទទួលយកសំណូមពរទៅពិចារណា ស្វែងរកភស្តុតាងដាក់បន្ទុក។

តាមស្មារតីអង្គប្រជុំ ឯកឧត្តមព្រះរាជអាជ្ញា និងធ្វើការពិនិត្យទៅលើធាតុចូលទាំងនេះដើម្បីធ្វើការដោះស្រាយសមរម្យអាចទទួលយកបាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកជំទាវអនុប្រធានអចិន្ត្រៃយ៍មេត្តាជ្រាបជារបាយការណ៍។

ដោយក្តីគោរពពីនាងខ្ញុំ។

អ្នកធ្វើរបាយការណ៍

**អគ្គលេខាធិការរង**

រ៉េន_សិរីវិសក្ខិណា

ចម្លងជូន:

- ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ
- ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី
- ឯកសារកាលប្បវត្តិ